# ប្រវត្តិរូបសង្ខេប
# សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

**មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**រៀបចំ និង ចងក្រងដោយ**

ផ្នែកបណ្តុះបណ្តាល និង ទំនាក់ទំនងនៃ

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល

**លោក វិណ្ណដេត តារារដ្ឋ**

**លោក អ៊ី សំភី**

បោះពុម្ពដោយមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល

© រក្សាសិទ្ធិឆ្នាំ២០១០

# មាតិកា


បញ្ជីឈ្មោះអាជ្ញាកណ្ដាលស្នើដោយក្រសួងការងារ ......................................១

លោក អាំង អេងថុង
បណ្ឌិត សុខ ម៉ាធឿង
លោក គង់ ផល្លះ
លោក គឹម យាតដារ៉ារិទ្ធ
លោក ប៉ែន ប៊ុនឈា
លោក ម៉ែន និម្មិត
លោក ញ្ញាន សុមុន្និន្ទ
លោក តាំង ទ្រី
លោក រុន សារ៉ាយ
លោក កុយ នាម

បញ្ជីឈ្មោះអាជ្ញាកណ្ដាលស្នើដោយសមាគមនិយោជក ................................៧

លោកស្រី ឈឹវ គិរម្យ
លោក ហែម ហួណារិទ្ធ
លោក អ៊ុំង សុទ្ធី
លោកស្រី សេង ឡូចហ៊ុន
លោក គល់ វឌ្ឍនា
លោក លី តៃសេង
លោក ម៉ារ សំបូរណា
លោក អ៊ុក វី
លោក កៅ ថាច
កញ្ញា យូ សួនធី

បញ្ជីឈ្មោះអាជ្ញាកណ្ដាលស្នើដោយសហជីព កម្មករនិយោជិត .......................១៣

លោកស្រី អាន វីរៈ
លោក លីវ សុវណ្ណា
លោក អន ណាន
លោក វ៉ែន ពៅ
លោក ហួន ជុនឌី
លោក សុង វណ្ណស៊ីន
លោក សួង សុផល
លោកស្រី ស៊ីន គីមស៊ាន
លោក ទួន ស៊ីផាន់
លោក វង្ស វណ្ណា

# បញ្ជីឈ្មោះអាជ្ញាកណ្តាល
# ស្នើដោយក្រសួងការងារ

## អាជ្ញាកណ្តាលតែងតាំងតាមប្រការ ៣ក នៃប្រកាសស្តីពី
## ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

## លោក អាំង អេងថុង



មុខងារបច្ចុប្បន្នៈ នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី (ភ្នំពេញ)។

ប្រវត្តិសង្ខេបៈ សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ អតីតប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ អតីតស្ថាបនិក និងអគ្គលេខាធិការនៃសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា។ អតីតបុគ្គលិកនៃរាជាយស្វ័យយាន្ត នៃព្រះរាជាណាចក្រកម្ពុជា។ អតីតសាស្ត្រាចារ្យភាសាបារាំង។ ប្រធានផ្នែកឃ្លាំងទំនិញ និង ប្រធានគ្រប់គ្រងថវិការសាងសង់ផ្លូវដែកពីភ្នំពេញទៅក្រុងព្រះសីហនុ។ អតីតប្រធានដឹកនាំបណ្តឹងតុលាការរបស់រាជាយស្វ័យយាន្ត នៃព្រះរាជាណាចក្រកម្ពុជា។

កំរិតវប្បធម៌ៈ បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ភ្នំពេញ ឆ្នាំ១៩៦៥)

ភាសាៈ ខ្មែរ បារាំង (ស្ទាត់ជំនាញ) អង់គ្លេស (មធ្យម)

## បណ្ឌិត សុខ ម៉ាឆឿង



មុខងារបច្ចុប្បន្នៈ សាស្ត្រាចារ្យសេដ្ឋកិច្ចនិងច្បាប់ បង្រៀនវិទ្យាសាស្ត្រសេដ្ឋកិច្ចគ្រប់គ្រងដល់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រង (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សាលាភូមិន្ទរដ្ឋបាល និងសាកលវិទ្យាល័យដ៏ទៃទៀត នៅភ្នំពេញនិងតាមខេត្តនានា។ អ្នកផ្សះផ្សាដែលមានការទទួលស្គាល់ពីមជ្ឈមណ្ឌលសន្ទានកម្មនិងមជ្ឈត្តកម្ម នៃទីក្រុងប៉ារីស ប្រទេសបារាំង។

ប្រវត្តិសង្ខេបៈ អតីតសាស្ត្រាចារ្យនីតិការងារ នៃមហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យបៀលប្រាយ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ អតីតសាស្ត្រាចារ្យវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមមាននីតិសេដ្ឋកិច្ចសាធារណៈ នៅមហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងនៅសាលាភូមិន្ទរដ្ឋបាល ប្រទេសកម្ពុជា ហើយនិងសាកលវិទ្យាល័យប៉ារីស ប្រទេសបារាំង។ មន្ត្រីកម្មវិធីនៃសហគមន៍អឺរ៉ុបប្រចាំនៅទីក្រុងភ្នំពេញ។

កំរិតវប្បធម៌ៈ បណ្ឌិតវិទ្យាសាស្ត្រសេដ្ឋកិច្ច (ប្រទេសបារាំង)។ បរិញ្ញាប័ត្រសេដ្ឋកិច្ច និង បរិញ្ញាប័ត្រនីតិសាស្ត្រ ពីមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា។

ភាសាៈ ខ្មែរ អង់គ្លេស បារាំង

## លោក គង់ ផល្លះ



មុខងារបច្ចុប្បន្ន: ប្រធានក្រុមមេធាវី នៃការិយាល័យមេធាវីខ្មែរលិកស៍។ ព្រឹទ្ធបុរសនិងសាស្ត្រាចារ្យ (មហាវិទ្យាល័យច្បាប់និងកិច្ចការសាធារណៈ នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា) បង្រៀនថ្នាក់បរិញ្ញាបត្រ និងអនុបណ្ឌិតលើមុខវិជ្ជា ដូចជា *នីតិរដ្ឋធម្មនុញ្ញ នីតិពាណិជ្ជកម្ម ប្រព័ន្ធអង្គការសហប្រជាជាតិ នីតិសាធារណៈ នីតិការងារ ប្រព័ន្ធនយោបាយប្រៀបធៀប ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប្រវត្តិនិងប្រព័ន្ធច្បាប់របស់អាស៊ាន នីតិពាណិជ្ជកម្មកំរិតខ្ពស់ ច្បាប់កិច្ចសន្យា និងអំពើនីត្យានុកូល* ។

ប្រវត្តិសង្ខេប: អ្នកជំនាញច្បាប់ និង ទីប្រឹក្សាសម្រាប់គម្រោងតុលាការគំរូកម្ពុជា។ ទីប្រឹក្សាគម្រោងជំនួយផ្នែកច្បាប់របស់ USAID-EWMI និង គម្រោងសិក្សាទិន្នន័យមូលដ្ឋានរបស់អង្គការកិច្ចសហប្រតិការបច្ចេកទេសអាល្លឺម៉ង់ នៅក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ។ សមាជិកត្រួតពិនិត្យរបស់គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា សហការជាដៃគូរជាមួយជំនួយទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID-CCJAP)។ ជំនួយការច្បាប់នៃគម្រោងក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ប្រចាំនៅក្រសួងយុត្តិធម៌។ សាស្ត្រាចារ្យច្បាប់ (មហាវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) បង្រៀននីតិពាណិជ្ជកម្ម។

កំរិតវប្បធម៌: អនុបណ្ឌិតច្បាប់ (សាកលវិទ្យាល័យណាហ្គូយ៉ា មហាវិទ្យាល័យជាន់ខ្ពស់ផ្នែកច្បាប់ ប្រទេសជប៉ុន)។ បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា) ។ ទន្តបណ្ឌិត (សាកលវិទ្យាល័យភូមិន្ទសុខាភិបាល ប្រទេសកម្ពុជា)។

ភាសា: ខ្មែរ អង់គ្លេស (ស្ទាត់ជំនាញ) បារាំង ជប៉ុន (មធ្យម)

## លោក គីម យាតដារ៉ារិទ្ធ



មុខងារបច្ចុប្បន្ន: មេធាវី សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ប្រវត្តិសង្ខេប: អតីតនាយករងនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។ ទីប្រឹក្សាច្បាប់ និង មន្ត្រីគម្រោងនៃគណៈកម្មការអឺរ៉ុប ការិយាល័យសម្របសម្រួលនៅភ្នំពេញ។ នាយកក្រុមហ៊ុន Derruder កម្ពុជា។

កំរិតវប្បធម៌: បណ្ឌិតនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ប្រទេសបារាំង)។ អនុបណ្ឌិតវិទ្យាសាស្ត្រនយោបាយ (ប្រទេសបារាំង) ។ បរិញ្ញាប័ត្រគ្រប់គ្រងធនធានមនុស្ស (ប្រទេសបារាំង)។

ភាសា: ខ្មែរ អង់គ្លេស បារាំង

## លោក ប៉ែន ប៊ុនឈា



មុខងារបច្ចុប្បន្ន: អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និង ប្រព័ន្ធតុលាការ នៃទីស្តីការគណៈរដ្ឋមន្ត្រី។

ប្រវត្តិសង្ខេប: ប្រធានគម្រោងជំនួយផ្នែកច្បាប់ គាំទ្រដោយ USAID-EWMI (គម្រោងសិក្សាទិន្នន័យមូលដ្ឋាន) នៅក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ។ ប្រធានគម្រោងសេចក្តីព្រាងច្បាប់ គាំទ្រដោយអង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (គម្រោងសិក្សាទិន្នន័យមូលដ្ឋានអំពីអង្គភាពច្បាប់ និងសមត្ថភាពរបស់ក្រសួង និង ស្ថាប័ននានា ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់)។ នាយកគម្រោងព័ត៌មានវិទ្យានៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ។ អនុប្រធានគម្រោងរដ្ឋបាលទូទៅនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។ សាស្ត្រាចារ្យនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី (ភ្នំពេញ) បង្រៀនមុខវិជ្ជាទាក់ទងនឹង ការសរសេរកិច្ចសន្យា ការដោះស្រាយវិវាទ ការចរចារ ការផ្សះផ្សារ និងអាជ្ញាកណ្តាល។

កំរិតវប្បធម៌: អនុបណ្ឌិត គោលនយោបាយសាធារណៈ (ប្រទេសជប៉ុន)។ បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យនីតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា)។

ភាសា: ខ្មែរ អង់គ្លេស

## លោក ម៉ែន និម្មិត



មុខងារបច្ចុប្បន្ន: សមាជិកក្រុមប្រឹក្សាភិបាល នៃកម្មវិធីសាកលដើម្បីការងារកាន់តែប្រសើរ ដែលមានទីតាំងនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។ បេក្ខជនថ្នាក់បណ្ឌិតច្បាប់នៃមហាវិទ្យាល័យច្បាប់មែលប៊ន នៃប្រទេសអូស្ត្រាលី។

ប្រវត្តិរូបសង្ខេប: អតីតនាយកប្រតិបត្តិ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ទីប្រឹក្សាច្បាប់ (ការិយាល័យមេធាវីឯកជន)។ មន្ត្រីកម្មវិធីគម្រោងរបស់ទីភ្នាក់ងារ អាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ និងសហគមន៍អឺរ៉ុប។ សាស្ត្រាចារ្យច្បាប់ នៃមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

កំរិតវប្បធម៌: បរិញ្ញាប័ត្ររដ្ឋបាលសាធារណៈ (ប្រទេសថៃ)។ បរិញ្ញាប័ត្រច្បាប់ (ប្រទេសកម្ពុជា)។ អនុបណ្ឌិតច្បាប់ (ប្រទេសអាមេរិក)។

ភាសា: ខ្មែរ អង់គ្លេស ថៃ

## លោក ញាន សុមុន្និន្ទ



មុខងារបច្ចុប្បន្ន ៖ ទីប្រឹក្សាជាតិផ្នែកច្បាប់ អ្នកជំនាញផ្នែកច្បាប់ភូមិបាលនៃវិទ្យាស្ថានគ្រប់គ្រងបូព៌ាបស្ចឹម ។

ប្រវត្តិសង្ខេប: អ្នកពិគ្រោះយោបល់សម្រាប់គម្រោងផ្សេងៗ ទាក់ទងនឹងការតាក់តែងសេចក្តីព្រាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តិ និងផ្សព្វផ្សាយច្បាប់ភូមិបាលរបស់ UNICEF, GTZ-LMAP, DANIDA-NRLMP, ADB-EWMI និង EWMI-DRL-ECOSORN-USAID ។ ទីប្រឹក្សាក្នុងស្រុក សម្រាប់គម្រោងអភិបាលកិច្ចល្អរបស់អង្គការកិច្ចសហប្រត្តិការបច្ចេកទេសអាល្លឺម៉ង់ និង ធនាគារពិភពលោក។ គ្រូបង្រៀនច្បាប់ និង អ្នកបកប្រែជាមួយ សាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ គម្រោងមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៏ ។ ប្រធានផ្នែកលក់និងទីផ្សារ និង អ្នកគ្រប់គ្រងនៅក្រុមហ៊ុនឯកជនមួយចំនួន។ ជំនាញ និង ឯកទេសផ្នែកកិច្ចសន្យា និង ជំនាញដោះស្រាយវិវាទ ការចរចារ និង ការផ្សះផ្សារ/សន្ធានកម្ម និងអាជ្ញាកណ្តាលពាណិជ្ជកម្ម។

កំរិតវប្បធមិ ៖ សញ្ញាប័ត្រអនុបណ្ឌិត ផ្នែកអភិបាលកិច្ចនិងការអភិវឌ្ឍន៏ ពីវិទ្យាស្ថានសិក្សាអភិវឌ្ឍន៏នៃសាកលវិទ្យាល័យស៊ូសស៊ិក នៅចក្រភពអង់គ្លេស ។ និស្សិតស្រាវជ្រាវផ្នែកច្បាប់នៅមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យមីឈីហ្គែន សហរដ្ឋអាមេរិក។ បរិញ្ញាប័ត្រផ្នែកច្បាប់ពីវិទ្យាស្ថានជាតិគ្រប់គ្រងភ្នំពេញ។ បរិញ្ញាប័ត្រផ្នែកភូមិវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សិក្សាផ្នែកកំណត់ត្រាគណនេយ្យ នៅមហាវិទ្យាល័យ Regent College ភ្នំពេញ ។

ភាសា ៖ ខ្មែរ អង់គ្លេស ថៃ

## លោក តាំង ទ្រី



មុខងារបច្ចុប្បន្ន ៖ មេធាវី ។

ប្រវត្តិសង្ខេប: ទីប្រឹក្សាអាជីវកម្ម និងវិនិយោគទុននៅការិយាល័យមេធាវី Sciaroni & Associates ។ គ្រូបង្រៀនច្បាប់ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ។ គណនេយ្យករ និង មន្ត្រីផ្នែកត្រួតពិនិត្យ និងហិរញ្ញវត្ថុនៅក្រុមហ៊ុន Nestle Daily (Cambodia) Ltd. ។ មន្ត្រីផ្នែកហិរញ្ញវត្ថុនៅអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។

កំរិតវប្បធមិ: អនុបណ្ឌិតច្បាប់អន្តរជាតិសាធារណៈ នៅសាកលវិទ្យាល័យកានសាយ ទីក្រុងអូសាកា ប្រទេសជប៉ុន។ បរិញ្ញាប័ត្រច្បាប់ពាណិជ្ជកម្ម (វិទ្យាស្ថានជាតិគ្រប់គ្រង)។ បរិញ្ញាប័ត្ររដ្ឋបាលពាណិជ្ជកម្ម។

ភាសា: ខ្មែរ អង់គ្លេស ជប៉ុន

## លោក នូន សារ៉ាយ



មុខងារបច្ចុប្បន្ន: នាយកប្រតិបត្តិ នៃអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។

ប្រវត្តិសង្ខេប: អ្នកគ្រប់គ្រងទូទៅនៅអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ។ ទីប្រឹក្សាពាណិជ្ជកម្ម និង សេដ្ឋកិច្ចនៃមូលនិធិអាស៊ី។ នាយកគ្រប់គ្រងវេទិកាពាណិជ្ជកម្មដ៏ប្រសើរក្នុងអនុតំបន់មេគង្គ (GMS-BF) នៅប្រទេសឡាវ។ មន្ត្រីកម្មវិធីនៃមូលនិធិអាស៊ី មើលការខុសត្រូវលើអង្គការក្រៅរដ្ឋាភិបាលដែលទទួលមូលនិធិពីមូលនិធិអាស៊ី។ គ្រូបង្រៀនច្បាប់ នៅវិទ្យាស្ថានជាតិគ្រប់គ្រង និង សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

កំរិតវប្បធម៌: អនុបណ្ឌិតផ្នែកសេដ្ឋកិច្ច និងច្បាប់អន្តរជាតិ (វិទ្យាស្ថានពាណិជ្ជកម្មអន្តរជាតិ ប្រទេសស្វីស)។ បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា)។ បរិញ្ញាប័ត្រ ផ្នែកច្បាប់ពាណិជ្ជកម្ម (វិទ្យាស្ថានជាតិគ្រប់គ្រង)។ បរិញ្ញាប័ត្រ រដ្ឋបាលសាធារណៈ (ប្រទេសថៃ)។

ភាសា: ខ្មែរ អង់គ្លេស បារាំង

## លោក កុយ នាម



មុខងារបច្ចុប្បន្ន: មន្ត្រីកម្មវិធីជាន់ខ្ពស់ នៃអង្គការមូលនិធិអាស៊ី។

ប្រវត្តិសង្ខេប: និពន្ធនាយក នៃព្រឹត្តិប័ត្រអ្នកច្បាប់របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ សមាជិកគណៈកម្មាធិការកិច្ចការច្បាប់ព្រហ្មទណ្ឌនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។ ប្រធានកម្មវិធីអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍។ សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។ សាស្ត្រាចារ្យច្បាប់ នៃមហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យជាតិគ្រប់គ្រង និង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

បោះពុម្ពផ្សាយ: ដំណើរការក្តីនៅក្នុងតុលាការកម្ពុជា។ អយ្យការ : ប្រវត្តិ និងការសិក្សាប្រៀបធៀប។ វចនានុក្រមច្បាប់ភាសាអង់គ្លេស-ខ្មែរ។

កំរិតវប្បធម៌: អនុបណ្ឌិតច្បាប់ ផ្នែកកិច្ចការជំនួញអន្តរជាតិ និងនីតិប្រៀបធៀប ពីសាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ។ បរិញ្ញាប័ត្រវិស្វករគីមីវិទ្យា (ភ្នំពេញ)។

ភាសា: ខ្មែរ អង់គ្លេស បារាំង ថៃ

# បញ្ជីឈ្មោះអាជ្ញាកណ្តាល
# ស្នើដោយសមាគមនិយោជក

### អាជ្ញាកណ្តាលតែងតាំងតាម ប្រការ ៣ក នៃប្រកាសស្តីពី
### ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

## លោកស្រី ឈឹម តិរម្យ



មុខងារបច្ចុប្បន្ន: ប្រធានផ្នែកច្បាប់ និងអភិវឌ្ឍន៍ធនធានមនុស្ស និង រដ្ឋបាលនៅក្រុមហ៊ុនបំរើសេវាកម្មគ្រប់គ្រងអាកាសចរណ៍កម្ពុជា។ សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជំនាញផ្នែកកិច្ចសន្យាការងារ និង កិច្ចសន្យាសហគ្រាសពាណិជ្ជកម្ម។

ប្រវត្តិសង្ខេប: សាស្ត្រាចារ្យច្បាប់បង្រៀននីតិការងារ នៅសាកលវិទ្យាល័យបៀលប្រាយ និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

កំរិតវប្បធម៌: សញ្ញាប័ត្រអនុបណ្ឌិតផ្នែកច្បាប់ និង ទំនាក់ទំនងការងារនៅក្នុងសហគ្រាស ពីសាកលវិទ្យាល័យលីមីញៀរលីយ៉ុង ២ នៃប្រទេសបារាំង។ បរិញ្ញាប័ត្រ ផ្នែកនីតិឯកជន ពីសាកលវិទ្យាល័យ លីមីញៀរលីយ៉ុង ២ ។

ភាសា: ខ្មែរ អង់គ្លេស បារាំង

## លោក ហែម ហួរណារិទ្ធ



មុខងារបច្ចុប្បន្ន: ប្រធានការិយាល័យមេធាវី ប៊ីអេនជី (BNG Legal)។

ប្រវត្តិសង្ខេប: ធ្វើការនៅក្នុងមុខតំណែងផ្សេងៗ ក្នុងកិច្ចការសាធារណៈ (ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ) និងតួនាទីផ្សេងៗក្នុងវិស័យច្បាប់។ ឯកទេសច្បាប់ពាណិជ្ជកម្ម និង ហិរញ្ញវត្ថុ។

កំរិតវប្បធម៌: សញ្ញាប័ត្រអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី។ បរិញ្ញាប័ត្រច្បាប់ (វិទ្យាស្ថានជាតិគ្រប់គ្រង)។ ឱសថការីឧត្តម (មហាវិទ្យាល័យវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងឱសថសាស្ត្រ ភ្នំពេញ ប្រទេសកម្ពុជា) ។

ភាសា: ខ្មែរ អង់គ្លេស បារាំង

## លោក អ៊ុំ សុន្ធី



មុខងារបច្ចុប្បន្ន៖ គ្រូបង្រៀនច្បាប់ និង រដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យបៀលប្រាយ សាកលវិទ្យាល័យពុទ្ធិសាស្ត្រ និងសាកលវិទ្យាល័យឯកទេសនៃកម្ពុជា។ ប្រធានផ្នែកនីតិឯកជន នៅក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី។

ប្រវត្តិសង្ខេប៖ អតីតមន្ត្រីអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច។ អតីតមន្ត្រីអធិការកិច្ចរបស់រាជរដ្ឋាភិបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី។ អតីតមន្ត្រីបច្ចេកទេស នៅនាយកដ្ឋានអភិរក្ស និង ការពារធម្មជាតិ នៃក្រសួងបរិស្ថាន។

កំរិតវប្បធម៌៖ បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា)។ បេក្ខជនអនុបណ្ឌិតច្បាប់ នៅសាកលវិទ្យាល័យបៀលប្រាយ។ សញ្ញាប័ត្រឯកទេសពេទ្យសត្វ (ពី Armavir ប្រទេសរុស្ស៊ី)។

ភាសា៖ ខ្មែរ បារាំង (មធ្យម) រុស្ស៊ី (មធ្យម) អង់គ្លេស (មធ្យម)

## លោកស្រី សេង ទូចហ៊ុន



មុខងារបច្ចុប្បន្ន៖ ប្រធានការិយាល័យមេធាវី នៃក្រុមមេធាវីអាស៊ីកម្ពុជា។

ប្រវត្តិសង្ខេប៖ មន្ត្រីទំនាក់ទំនងគម្រោងយេនឌ័ររបស់គណៈមេធាវីកម្ពុជា និងសហព័ន្ធគណៈមេធាវីជប៉ុន។ ទីប្រឹក្សាក្រុមហ៊ុនអាល់ហ្វា អ៊ិនធើណេសិនណល ឌបភើរេសិន អិលធីឌី។ មន្ត្រីជំនួយការកម្មវិធី នៃវិទ្យាស្ថានសាធារណៈរដ្ឋអន្តរជាតិរបស់អាមេរិក ដែលមានទីតាំងនៅភ្នំពេញ។ គម្រោងច្បាប់គ្រួសារ របស់សាកលវិទ្យាល័យមីឈីហ្គែន (សហរដ្ឋអាមេរិក)។ ជំនួយការគម្រោងកិច្ចសហប្រតិបត្តិការច្បាប់ និងប្រព័ន្ធតុលាការដើម្បីធ្វើសេចក្តីព្រាងច្បាប់ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា។

កំរិតវប្បធម៌៖ អនុបណ្ឌិតច្បាប់ (សាលកវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា)។ បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា)។ វិញ្ញាបនប័ត្រផ្នែកកម្មវិធីស្រាវជ្រាវ ពីមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យមីឈីហ្គែន នៃសហរដ្ឋអាមេរិក។

ភាសា៖ ខ្មែរ អង់គ្លេស បារាំង

## លោក គល់ វឌ្ឍនា



មុខងារបច្ចុប្បន្ន: អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

ប្រវត្តិសង្ខេប: បទពិសោធន៍ក្នុងការដោះស្រាយវិវាទ ទាក់ទងនឹងការការពារតំបន់ និងសហគមន៍ដោយផ្អែកលើការគ្រប់គ្រងប្រភពធនធានធម្មជាតិ ។ បទពិសោធន៍ក្នុងការគ្រប់គ្រងពាណិជ្ជកម្មខ្នាតតូចក្នុងវិស័យនាំចេញ និងលក់រាយ ។ រៀបចំស្រាវជ្រាវឯកសារគោលនយោបាយទាក់ទងនឹងការគ្រប់គ្រងប្រភពធនធានធម្មជាតិ និង តំបន់ការពារនិងព្រៃឈើ សម្រាប់ការការពារ ។

កំរិតវប្បធម៌: បរិញ្ញាប័ត្រវិទ្យាសាស្ត្រព្រៃឈើ (សាកលវិទ្យាល័យកសិកម្ម ភ្នំពេញ) អនុបណ្ឌិតវិទ្យាសាស្ត្រផ្នែកដីស្រទាប់លើ ( ប្រទេសបែលហ្ស៊ិក) ។

ភាសា: ខ្មែរ អង់គ្លេស

## លោក លី តៃសេង



មុខងារបច្ចុប្បន្ន: មេធាវី និង ជានាយកគ្រប់គ្រងក្រុមមេធាវី HBS Law Firm & Consultants សារការី HBS ។

ប្រវត្តិសង្ខេប: អតីតអគ្គលេខាធិការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ ប្រធានខុទ្ទកាល័យនៃប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ ទីប្រឹក្សាច្បាប់នៃការិយាល័យមេធាវីក្នុងតំបន់ដែលមានទីតាំងនៅកម្ពុជា ។ គ្រូបង្រៀនច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជំនួយការទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនក្នុងគម្រោងធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ។ ជំនួយការច្បាប់នាយកសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

កំរិតវប្បធម៌: បរិញ្ញាប័ត្រច្បាប់ឯកជន (មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា) ។ បរិញ្ញាប័ត្រច្បាប់នីតិឯកជន ពីមហាវិទ្យាល័យលុយមីញែរ លីយ៉ុង២ នៅប្រទេសបារាំង ។ អនុបណ្ឌិតច្បាប់នៅសាកលវិទ្យាល័យណាហ្គូយ៉ា ជំនាញផ្នែកដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ ។

ភាសា: ខ្មែរ អង់គ្លេស បារាំង ជប៉ុន

## លោក ម៉ារ សំបូរណា



មុខងារបច្ចុប្បន្ន: ទីប្រឹក្សាជាន់ខ្ពស់ (ក្រុមមេធាវី Justice and Associates)។ ប្រធានផ្នែកកិច្ចការច្បាប់និងបទបញ្ជា (CamGSM Co., Ltd.) ។

ប្រវត្តិសង្ខេប: អតីតទីប្រឹក្សាជាន់ខ្ពស់នៅការិយាល័យមេធាវី Sciaroni & Associates។ ផ្តល់ការប្រឹក្សាយោបល់អំពីច្បាប់ស្តីពីការងារ និង ប្រឹក្សាសាជីវកម្ម និងនិយ័តកម្ម។

កំរិតវប្បធម៌: បរិញ្ញាប័ត្រច្បាប់ - នីតិសាធារណៈ (មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច) និង នីតិពាណិជ្ជកម្ម (វិទ្យាស្ថានជាតិគ្រប់គ្រងកម្ពុជា)។ អនុបណ្ឌិតវិទ្យាសាស្ត្រវិស្វកម្ម (សហភាពសូវៀត)។ អនុបណ្ឌិតច្បាប់ និង វិទ្យាសាស្ត្រនយោបាយ (សាកលវិទ្យាល័យ បៀលប្រាយកម្ពុជា)។

ភាសា: ខ្មែរ អង់គ្លេស រុស្សី

## លោក អ៊ុក រី



មុខងារបច្ចុប្បន្ន: ដៃគូរ ការិយាល័យមេធាវី Bou, Nou, Ouk & Partners Law Firm។

ប្រវត្តិសង្ខេប: សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ អតីតទីប្រឹក្សាច្បាប់ (ក្រុមហ៊ុន Dirksen Flipse Doran & Le - DFDL)។ មេធាវី នៅការិយាល័យច្បាប់មេគង្គហ្គ្រុប (Mekong Law Group)។ មេធាវីតាំងពីឆ្នាំ១៩៩៧ នៅក្នុងប្រទេសកម្ពុជា ដែលផ្តោតទៅលើកិច្ចសន្យា និងសេចក្តីព្រាងច្បាប់នានា ការស្រាវជ្រាវច្បាប់ និង គោលនយោបាយ ហើយនិងដំណោះស្រាយវិវាទការងារ និងវិវាទពាណិជ្ជកម្ម។ មេធាវី និង ស្នាក្តីមេធាវីនៅក្នុងតុលាការកំពូល ប្រទេសញូស៊ីឡែន។

កំរិតវប្បធម៌: អនុបណ្ឌិតច្បាប់ (ប្រទេសអូស្ត្រាលី)។ បរិញ្ញាប័ត្រច្បាប់ និង បរិញ្ញាប័ត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច (ប្រទេសញូស៊ីឡែន)។

ភាសា: ខ្មែរ អង់គ្លេស

## លោក គៅ ថាច



មុខងារបច្ចុប្បន្ន: អគ្គនាយករងគណកម្មការមូលប័ត្រ ។

ប្រវត្តិសង្ខេប: អតីតក្រឡាបញ្ជី នៅតុលាការខេត្តកោះកុង។ អតីតមន្ត្រីច្បាប់ នៅក្រសួងយុត្តិធម៌។ ប្រធានផ្នែកទីផ្សារ ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កំរិតវប្បធម៌: អនុបណ្ឌិតច្បាប់ នៃសាកលវិទ្យាល័យបូន ប្រទេសអូស្ត្រាលី។ បរិញ្ញាប័ត្រច្បាប់ ពីមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា)។

ភាសា: ខ្មែរ អង់គ្លេស បារាំង

## កញ្ញា យុ សួនធី



មុខងារបច្ចុប្បន្ន: ទីប្រឹក្សាឯករាជ្យ។

ប្រវត្តិសង្ខេប: ផ្តល់ការប្រឹក្សា ដល់អង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ ក្រុមប្រឹក្សាស្តារនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជាសហភាពដើម្បីអភិរក្សពិភពលោក និងកម្មវិធីអង្គការសហប្រជាជាតិដើម្បីកិច្ចអភិវឌ្ឍន៍។ មន្ត្រីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម (MPDF)។ ទីប្រឹក្សាផ្នែកច្បាប់និងពន្ធដារ (ក្រុមហ៊ុន Dirksen Flipse Doran & Le - DFDL) ការងារទាក់ទងនឹងពន្ធដារ និង ការវិនិយោគទុន។ ទីប្រឹក្សាជាន់ខ្ពស់ផ្នែកពន្ធដារ (ក្រុមហ៊ុន PricewaterhouseCoopers Cambodia) ការងារទាក់ទងនឹងសេវាកម្មប្រឹក្សាយោបល់អំពីពន្ធដារ និងការត្រួតពិនិត្យលើការគោរពច្បាប់ស្តីពីការងារដោយរោងចក្រកាត់ដេរ។ ជំនួយការច្បាប់ (កម្មវិធីសហប្រជាជាតិ ដើម្បីកិច្ចអភិវឌ្ឍន៍ - UNDP) ។

កំរិតវប្បធម៌: អនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈ (មហាវិទ្យាល័យកិច្ចការសាធារណៈ និងអន្តរជាតិ នៃសាកលវិទ្យាល័យខូឡុមបៀរ សហរដ្ឋអាមេរិក។ អនុបណ្ឌិតច្បាប់ និង វិញ្ញាបនប័ត្រច្បាប់ពន្ធដារ (មហាវិទ្យាល័យច្បាប់ចេមបេស្លី នៃសាកលវិទ្យាល័យឌិមផល (សហរដ្ឋអាមេរិក)។ បរិញ្ញាប័ត្រច្បាប់ (វិទ្យាស្ថានជាតិគ្រប់គ្រង ប្រទេសកម្ពុជា)។ បរិញ្ញាប័ត្រគ្រប់គ្រងជំនួញ (មហាវិទ្យាល័យពាណិជ្ជកម្ម នៃសាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ និង សាកលវិទ្យាល័យចចថោន ប្រទេសកម្ពុជា)។ វិញ្ញាបនប័ត្របញ្ចប់ការសិក្សាអំពីច្បាប់ស្តីពីការងារ (ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា)។

ភាសា: ខ្មែរ អង់គ្លេស

# បញ្ជីឈ្មោះអាជ្ញាកណ្ដាល
# ស្នើដោយសហជីព កម្មករនិយោជិត

### អាជ្ញាកណ្ដាលតែងតាំងតាម ប្រការ ៣ក នៃប្រកាសស្ដីពី
### ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្ដាល

## លោកស្រី អាន ថិរៈ



មុខងារបច្ចុប្បន្ន: នាយកប្រតិបត្តិ នៃសមាហរណ៍កម្មធនធានឆ្ពោះទៅគុណភាព ។

ប្រវត្តិសង្ខេប: អតីតប្រធានកម្មវិធីច្បាប់ការងារ នៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍។ ធ្វើការយ៉ាងជិតស្និតជាមួយនឹងមេធាវីអន្តរជាតិ ដើម្បីបង្កើតយុទ្ធសាស្ត្រក្នុងការលើកកម្ពស់ការចរចារអនុសញ្ញារួម នៅក្នុងវិស័យការងារ។ បង្រៀនវគ្គបណ្តុះបណ្តាលជាង ៣០០វគ្គស្តីអំពី: ច្បាប់ការងារ ជំនាញក្នុងការប្រាស្រ័យទាក់ទង ជំនាញក្នុងការចរចារ និងជំនាញដោះស្រាយវិវាទ ដល់អង្គការដែលមិនស្វែងរកចំណេញ និង ក្រុមហ៊ុនឯកជន រួមមានដូចជា អ្នកគ្រប់គ្រងជាន់ខ្ពស់ មេធាវី ចៅក្រម អ្នកផ្សះផ្សារ កម្មករ សហជីព និងមន្ត្រីនរគរបាល និងធ្វើសិក្ខាសាសាស្តីអំពីច្បាប់ការងារ ដល់មន្ត្រីសំខាន់ៗ ពីព្រឹទ្ធសភារដ្ឋសភា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និង អ្នកប្រឹក្សាច្បាប់ក្នុងស្រុក។ ធ្វើសវនកម្មអំពីការគោរពច្បាប់ អោយអ្នកបញ្ជាទិញអន្តរជាតិដូចជា Nike Adidas Group និង ផ្តល់ប្រឹក្សាយោបល់ក្នុងការត្រួតពិនិត្យឡើងវិញនូវនីតិវិធី និង គោលនយោបាយគ្រប់គ្រងបុគ្គលិករបស់សហគ្រាស ដែលផ្គត់ផ្គង់ទំនិញដល់អ្នកបញ្ជាទិញទាំងនោះ។

កំរិតវប្បធម៌: បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)។ និស្សិតអាហារូបករណ៍ធ្វើទស្សនៈកិច្ចសិក្សាស្រាវជ្រាវ នៅមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យមីឈីហ្កែន សហរដ្ឋអាមេរិក។ វិញ្ញាបនបត្រ័ច្បាប់ជាន់ខ្ពស់ពីសាកលវិទ្យាល័យមីឈីហ្កែន និងធ្លាប់បានសិក្សាជំនាញផ្សះផ្សារនិងចរចារ នៅប្រទេសអូស្ត្រាលី។

ភាសា: ខ្មែរ អង់គ្លេស

## លោក លីវ សុវណ្ណា



មុខងារបច្ចុប្បន្ន: មេធាវី។

ប្រវត្តិសង្ខេប: មេធាវីធ្វើការនៅក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ។ ស្ថាបនិក និងជាអតីតអនុប្រធានសហព័ន្ធសហជីពខ្មែរ។ តំណាងឱ្យសហព័ន្ធសហជីពខ្មែរ ក្នុងការដោះស្រាយវិវាទការងារ និងផ្តល់ការបណ្តុះបណ្តាលដល់សមាជិកសហជីព។ អតីតអ្នកច្បាប់ការពារសិទ្ធិនៃអង្គការហ្វីកហ្វីនសិទ្ធិមនុស្សកម្ពុជា ។

កំរិតវប្បធម៌: អនុបណ្ឌិតច្បាប់ (សាកលវិទ្យាល័យឯកទេសនៃកម្ពុជា)។ បរិញ្ញាប័ត្រច្បាប់ (សាលាអប់រំវិជ្ជាជីវៈមេធាវីប្រទេសកម្ពុជា)។

ភាសា: ខ្មែរ

## លោក អន ណាន



មុខងារបច្ចុប្បន្ន: ទីប្រឹក្សារបស់សមាគមសិទ្ធិកម្មករ ដែលមានទីតាំងធំនៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី (សហរដ្ឋអាមេរិក)។

ប្រវត្តិសង្ខេប: ទីប្រឹក្សាមជ្ឈមណ្ឌលអាមេរិកកាំង សម្រាប់សាមគ្គីភាពការងារអន្តរជាតិ។ អតីតប្រធានគ្រប់គ្រងផ្នែកច្បាប់ នៃអង្គការការងារកម្ពុជា។ គ្រូបណ្តុះបណ្តាលនៃសម្ព័ន្ធអង្គការហ្វឹកហ្វឺនការងារកម្ពុជា។ ការងារជាមួយនឹងអង្គការការងារកម្ពុជា ទាក់ទងនឹងការបណ្តុះបណ្តាលដល់កម្មករ ផ្តល់ទីប្រឹក្សាដល់សហជីព និងការដោះស្រាយវិវាទការងារ។

កំរិតវប្បធម៌: បរិញ្ញាបត្រច្បាប់ (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា)។ បរិញ្ញាប័ត្រវិទ្យាសាស្ត្រ (សាកលវិទ្យាល័យភូមិន្ទកសិកម្ម)។ បញ្ចប់វគ្គបណ្តុះបណ្តាលជាច្រើន អំពីច្បាប់ការងារ ពីសាកលវិទ្យាល័យ សាន់ហ្វ្រាន់ស៊ីស្កូ នៅក្រុងភ្នំពេញ និងវគ្គដោះស្រាយវិវាទ ពីវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។

ភាសា: ខ្មែរ អង់គ្លេស

## លោក ម៉ែន ពៅ



មុខងារបច្ចុប្បន្ន: មេធាវីនៅការិយាល័យមេធាវីខ្មែរ និងសហការី។

ប្រវត្តិសង្ខេប: ទីប្រឹក្សាច្បាប់ (សាខារបស់ Danny C. Campbell Professional Corporation ប្រចាំនៅកម្ពុជា)។ មេធាវីនៅការិយាល័យមេធាវីកម្ពុជា។ ប្រធានអង្គភាពការពារសិទ្ធិកុមារ នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ អតីតជំនួយការជាន់ខ្ពស់ផ្នែកទិដ្ឋាការជនអន្តោប្រវេសន៍ ជំនួយការប្រឆាំងនឹងអំពើបោកបន្លំផ្នែកកុងស៊ុលនៅស្ថានទូតអាមេរិក ប្រចាំនៅកម្ពុជា។ សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

កំរិតវប្បធម៌: បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ភ្នំពេញ)។ វិញ្ញាបនប័ត្រផ្នែកប្រវត្តិវិទ្យា និង ភូមិវិទ្យា និងវិញ្ញាបនប័ត្រផ្នែករដ្ឋបាលសាធារណៈ (ប្រទេសថៃ)។

ភាសា: ខ្មែរ អង់គ្លេស

# លោក ហួន ជុនឌី



មុខងារបច្ចុប្បន្ន: មេធាវីជាន់ខ្ពស់ និងប្រធានកម្មវិធីនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ។

ប្រវត្តិសង្ខេប: មេធាវីតាំងពីឆ្នាំ១៩៩៧។ អតីតមេធាវី និងអ្នកគ្រប់គ្រងគំរោងដំណើរការក្តីអនីតិជនរបស់អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។ មេធាវីជាន់ខ្ពស់ និងប្រធានអង្គភាពនៃកម្មវិធីដីធ្លី និងធនធានធម្មជាតិ នៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ដែលការពារក្តីនៅតុលាការ និងធ្វើការតស៊ូមតិក្នុងជម្លោះដីធ្លីនិងធនធានធម្មជាតិ។ មេធាវីជាន់ខ្ពស់ និងប្រធានកម្មវិធី នៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ដឹកនាំ និង គ្រប់គ្រងកម្មវិធីទាំងអស់របស់មជ្ឈមណ្ឌល រួមមានកម្មវិធីដីធ្លីនិងធនធានធម្មជាតិ កម្មវិធីច្បាប់ការងារ កម្មវិធីសម្រាប់ការទទួលបានយុត្តិធម៌ និងអភិបាលកិច្ចល្អ។

កំរិតវប្បធម៌: បរិញ្ញាប័ត្ររដ្ឋបាលសាធារណៈ (ប្រទេសកម្ពុជា) ។

ភាសា: ខ្មែរ អង់គ្លេស ថៃ

# លោក សុខ វណ្ណស៊ីន



មុខងារបច្ចុប្បន្ន: មន្រ្តីកម្មវិធីច្បាប់នៃសហគមន៍អឺរ៉ុប (ផ្នែកអភិបាលកិច្ច) ។

ប្រវត្តិសង្ខេប: បទពិសោធន៍ក្នុងការដោះស្រាយវិវាទដីធ្លី។ ធ្លាប់បង្រៀនផ្នែកមជ្ឈត្តកម្ម និងសន្ទានកម្មនៅប្រទេសកម្ពុជា និងនៅសហរដ្ឋអាមេរិក។ បង្រៀនវគ្គដោះស្រាយក្រៅប្រព័ន្ធតុលាការដល់អង្គការក្នុងស្រុក និងអាជ្ញាធរមូលដ្ឋាន ជាពិសេសអំពីយន្តការដោះស្រាយវិវាទដីធ្លី។ ធ្វើការស្រាវជ្រាវជាច្រើន ដើម្បីជួយគាំទ្រដល់ការតស៊ូមតិឱ្យមានការអនុម័តកំណែទំរង់គោលនយោបាយ និង ច្បាប់ដីធ្លី។ ជំនួយការច្បាប់ (គម្រោងកំណែទំរង់រដ្ឋបាល និងគម្រោងបណ្តុះបណ្តាលស្តីពីតុលាការកម្ពុជា របស់កម្មវិធីអង្គការសហប្រជាជាតិដើម្បីកិច្ចអភិវឌ្ឍន៍ ដែលមានគោលដៅចំបងផ្តោតទៅលើច្បាប់នីតិវិធី ក្នុងកំឡុងពេលបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញា។

កំរិតវប្បធម៌: បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ភ្នំពេញ)។ អនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈ (សាកលវិទ្យាល័យកម្ពុជា) ។

ភាសា: ខ្មែរ អង់គ្លេស

## លោក ស្ងួន សុផល



មុខងារបច្ចុប្បន្ន: មេធាវី និងគ្រូបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ។

ប្រវត្តិសង្ខេប: បណ្តុះបណ្តាលអំពីច្បាប់ការងារដល់សកម្មជនសហជីព។ មេធាវីនៅការិយាល័យមេធាវីឯកជន។ ធ្វើការជាជំនួយការច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី (ខុទ្ទកាល័យនាយករដ្ឋមន្ត្រី) ។ ធ្វើការជាមេធាវីការពារក្តី នៅផ្នែកជំនួយច្បាប់នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ សមាជិក នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

កំរិតវប្បធម៌: បរិញ្ញាប័ត្រច្បាប់ (មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ភ្នំពេញ) ។

ភាសា: ខ្មែរ អង់គ្លេស

## លោកស្រី ស៊ីន គីមស៊ាន



មុខងារបច្ចុប្បន្ន: អ្នកសម្របសម្រួលទំនាក់ទំនងគណៈមេធាវី និងមូលនិធិជំនួយផ្នែកច្បាប់របស់វិទ្យាស្ថានគ្រប់គ្រងបូពិបស៊ីម ។

ប្រវត្តិសង្ខេប: អ្នកគ្រប់គ្រងមូលនិធិជាន់ខ្ពស់ នៅវិទ្យាស្ថានគ្រប់គ្រងបូពិបស៊ីម (ទាក់ទងទៅនឹងបញ្ហាសិទ្ធិមនុស្ស និងនីតិរដ្ឋ) ។ មន្ត្រីកម្មវិធីមូលនិធិអាស៊ីទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស ភាពក្រីក្រ និងយេនឌ័រ។ គ្រូបង្រៀនច្បាប់នៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ដែលជាអតីតកម្មវិធីរបស់សាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ បណ្តុះបណ្តាលអំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ជំនួយការច្បាប់ នៃមជ្ឈមណ្ឌលស្រាវជ្រាវឯកសារច្បាប់។ មន្ត្រីកម្មវិធីនៃអង្គការក្រុមកិច្ចការ ពិសេសផ្នែកសិទ្ធិមនុស្សនៅកម្ពុជា។

កំរិតវប្បធម៌: អនុបណ្ឌិតផ្នែកច្បាប់អន្តរជាតិនិងសេដ្ឋកិច្ច (វិទ្យាស្ថានពាណិជ្ជកម្មអន្តរជាតិប្រទេសស្វីស) ។ បរិញ្ញាប័ត្រច្បាប់ ផ្នែកនីតិសាធារណៈ និងនីតិឯកជន (មហាវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកម្ពុជា) ។ បរិញ្ញាប័ត្រច្បាប់ផ្នែកនីតិពាណិជ្ជកម្ម (វិទ្យាស្ថានជាតិគ្រប់គ្រងកម្ពុជា) ។ វិញ្ញាបនប័ត្រកម្មវិធីស្រាវជ្រាវច្បាប់ (មហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យមីឈីហ្គែន សហរដ្ឋអាមេរិក) ។ បញ្ចប់វគ្គសិក្សាស្តីពីភាពជាអ្នកដឹកនាំ ពីសាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក។ វិញ្ញាបនប័ត្រច្បាប់ស្តីពីការងារកម្ពុជា (សាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ ប្រទេសកម្ពុជា) ។

ភាសា: ខ្មែរ អង់គ្លេស

## លោក ទួន ស៊ីផាន់



មុខងារបច្ចុប្បន្ន: ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនៃទីស្តីការគណៈរដ្ឋមន្ត្រី។

ប្រវត្តិសង្ខេប: ប្រធានផ្នែកសិក្សានិងគ្រូបង្រៀនច្បាប់ នៅមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ដែលជាអតីតកម្មវិធី របស់សាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ (មុខងារនេះទាក់ទិននឹងការបង្រៀនច្បាប់ស្តីពីការងារ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ)។ ចូលរួមចំណែករៀបរៀងសៀវភៅសិក្សាច្បាប់ ដូចជាសៀវភៅច្បាប់ស្តីពីការងារ និងដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាដើម។ អនុប្រធាននាយកដ្ឋានពិធីការ និង ទំនាក់ទំនងអន្តរជាតិនៅរដ្ឋសភាជាតិ។ មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

កំរិតវប្បធម៌: អនុបណ្ឌិតផ្នែកទំនាក់ទំនងអន្តរជាតិ (សហភាពសូវៀត)។ បរិញ្ញាប័ត្រច្បាប់ចំនួនពីរ (មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងវិទ្យាស្ថានជាតិគ្រប់គ្រងកម្ពុជា)។ និស្សិតស្រាវជ្រាវច្បាប់ (សាកលវិទ្យាល័យមីឈីហ្គែន សហរដ្ឋអាមេរិក)។ បញ្ចប់វគ្គបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ (មហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក)។

ភាសា: ខ្មែរ អង់គ្លេស រុស្ស៊ី

## លោក វង្ស វណ្ណា



មុខងារបច្ចុប្បន្ន: អនុប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រ និងវប្បធម៌ខ្មែរ។ សាស្ត្រាចារ្យច្បាប់ បង្រៀននីតិការងារ នៅសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ប្រវត្តិសង្ខេប: ធ្វើការនៅក្នុងវិស័យច្បាប់ការងាររយៈពេល៣០ឆ្នាំ នៅក្រសួងការងារ។ បំរើការជាប្រធាននាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ របស់ក្រសួងការងាររយៈពេល៧ឆ្នាំ។ រួមចំណែកក្នុងការរៀបចំសេចក្តីព្រាងបទដ្ឋានរដ្ឋបាលទាក់ទងនឹងច្បាប់ការងារ និងច្បាប់ស្តីពីការងារ ឆ្នាំ១៩៩២ និង ឆ្នាំ១៩៩៧។

កំរិតវប្បធម៌: បរិញ្ញាប័ត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច (មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចភ្នំពេញ) ។

ភាសា: ខ្មែរ បារាំង អង់គ្លេស